ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តគម្រោង ផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅ នឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍

(ប្រចាំឆ្នាំ២០១៨)

រៀបចំដោយអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ

ខែកុម្ភៈ ២០១៩

# សេចក្តីថ្លែងអំណរគុណ

ជាបឋមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍទាំងអស់ដែលបានផ្តល់នូវទិន្នន័យ ព័ត៌មាន និងរបាយការណ៍ប្រចាំឆ្នាំ ២០១៨ ទាន់ពេលវេលាដែលអាចឱ្យអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ប្រើប្រាស់ក្នុងការរៀបចំចងក្រងជារបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ បានគ្រប់ជ្រុងជ្រោយទូលំទូលាយ និងពហុវិស័យប្រចាំឆ្នាំ២០១៨ ទោះបីមានការយឺតយ៉ាវនិងមិនទាន់បានគ្រប់ស្ថាប័នទាំងអស់ក៏ដោយក៏របាយការណ៍នាពេលនេះកាន់តែមានភាពប្រសើរជាងមុន។

សូមសំដែងនូវការកោតសរសើរផងដែរ ជូនចំពោះអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានដឹកនាំ និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពខ្ពស់ លើការងាររៀបចំរបាយការណ៍នេះ ជាពិសេសនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវ និងក្រុមការងារទាំងអស់ដែលបានខិតខំយ៉ាងសកម្មក្នុងការប្រមូល វិភាគទិន្នន័យ និងចងក្រងនូវព័ត៌មានទាំងអស់ដែលទាក់ទងនឹងវឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅកម្ពុជាឱ្យមានរូបរាងឡើងជារបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រយុទ្ធនឹងជំងឺអេដស៍ប្រចាំឆ្នាំ២០១៨ ប្រកបដោយភាពជោគជ័យ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍នេះពិតជាឆ្លុះបញ្ចាំងនូវការពិតស្តីពីបច្ចុប្បន្នភាពនៃការឆ្លើយតបជាតិទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅកម្ពុជា និងអាចយកទៅប្រើប្រាស់ ក្នុងការសម្រេចចិត្តលើកកម្ពស់ការអនុវត្តផែនការសកម្មភាពជាតិជាបន្តទៀតឱ្យបានកាន់តែប្រសើរថែមទៀត នៅក្នុងចំណោមស្ថាប័នជាតិ អន្តរជាតិ ស្ថាប័នសង្គមស៊ីវិល ដៃគូអភិវឌ្ឍ ស្ថាប័នឯកជន។ល។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែ មាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៩

**ទេសរដ្ឋមន្ត្រី**

**ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**អៀង_មូលី**

# មាតិកា


សេចក្តីថ្លែងអំណរគុណ

ពាក្យកាត់ និងពាក្យបំព្រួញ

បញ្ជីរូបភាព

១. សេចក្តីផ្តើម.......................................................................................................១

១.១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍..........................................................................១

១.២. គម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគ អេដស៍និងជំងឺអេដស៍នៅឆ្នាំ២០១៨ ................................................................១

២. គោលបំណង និងកម្មវត្ថុ...........................................................................................២

៣. វិធីសាស្ត្រ...........................................................................................................២

៤. វឌ្ឍនភាព និងសមិទ្ធផល ........................................................................................៣

៤.១. យុទ្ធសាស្ត្រទី១: ផ្តួចផ្តើមការបង្ការមេរោគអេដស៍ដោយផ្តោតលើអន្តរាគមន៍ ដែលបង្កើនការគ្រប ដណ្តប់ដែលមានគុណភាពនិងប្រសិទ្ធភាពនៃអន្តរាគមន៍បង្ការ............................................៣

៤.២. យុទ្ធសាស្ត្រទី២: បង្កើន និងរក្សាគុណភាព ការគ្របដណ្តប់ និងការរក្សាទុកគ្រប់ជំហានទាំង អស់នៅក្នុងការថែទាំបន្តដោយយកភ័ស្តុតាង និងការណែនាំមូលដ្ឋាន.................................១០

៤.៣. យុទ្ធសាស្ត្រទី៣: កាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈការគ្រប ដណ្តប់អន្តរាគមន៍ដែលមានគុណភាព និងប្រសិទ្ធភាព.................................................១៥

៤.៤. យុទ្ធសាស្ត្រទី៤: ការដឹកនាំសម្របសម្រួលភាគីពាក់ព័ន្ធ ការកៀរគរនិងបែងចែកធនធាន (ជាយុទ្ធសាស្ត្រពាក់ព័ន្ធ នឹងយុទ្ធសាស្ត្រទាំង៥ទៀត).....................................................១៥

៤.៥. យុទ្ធសាស្ត្រទី៥: បង្ក និងបង្កើតបរិស្ថានការគាំទ្រតាមរយៈការយល់ដឹង និងការអនុវត្តច្បាប់ និងគោលនយោបាយឱ្យកាន់តែប្រសើរឡើង ...........................................................១៨

៤.៦. យុទ្ធសាស្ត្រទី៦: បង្កើនប្រព័ន្ធតាមដាននិងវាយតម្លៃការឆ្លើយតបមេរោគអេដស៍និងជំងឺអេដស៍ តែមួយ(ទាំងក្នុងវិស័យសុខភាព និងវិស័យដទៃទៀត)(ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ ទាំង៥ទៀត)........................................................................................................១៩

៥. សេចក្តីសន្និដ្ឋាន ...............................................................................................២០

៦. ដែនកំណត់ .......................................................................................................២០

៧. អនុសាសន៍ .......................................................................................................២១

ឯកសារយោង

# ពាក្យកាត់ និងពាក្យបំព្រួញ

| | |
|---|---|
| អ ជ ប ជ អ | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ |
| AIDS | Acquired Immune Deficiency Syndrome ( ជំងឺអេដស៍ ) |
| AHF | AIDS Healthcare Foundation (មូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍ ) |
| ARV | Anti-Retroviral ( ឱសថប្រឆាំងនឹងមេរោគអេដស៍ ) |
| ART | Anti-Retroviral Therapy ( ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ) |
| CCC | Country Coordinating Committee ( គណៈកម្មាធិការសម្របសម្រួលមូលនិធិសកលប្រចាំប្រទេសកម្ពុជា ) |
| CPN+ | Cambodian Network of People Living with HIV/AIDS ( បណ្តាញអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា ) |
| FHI360 | Family Health International 360 (អង្គការសុខភាពគ្រួសារ360) |
| GARPR | Global AIDS Response Progress Reporting ( របាយការណ៍វឌ្ឍនភាព ឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាសកល ) |
| HIV | Human Immunodeficiency Virus ( មេរោគអេដស៍ ) |
| HP+ | Health Policy plus |
| IBBS | Integrated Biological Behavioral Surveillance ការអង្កេតពីជីវសាស្ត្រ និងការប្រព្រឹត្តបញ្ចូលគ្នា |
| NAA | National AIDS Authority ( អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ) |
| NASA | National AIDS Spending Assessment ( ការអង្កេតស្តីពីការចំណាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ ) |
| NCHADS | National Centre for HIV/AIDS, Dermatology and STDs ( មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ) |
| NMCHC | National Mother Child Health Center (មជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក ) |
| OI | Opportunistic Infection (ជំងឺឱកាសនិយម ) |
| PSI Cambodia | Population Services International Cambodia (អង្គការអន្តរជាតិបំរើសេវាជូនប្រជាជនកម្ពុជា ) |
| SMS | Short Message Service (ប្រព័ន្ធផ្ញើសារខ្លីៗតាមទូរស័ព្ទ ) |
| STI | Sexually Transmitted Infection ( ជំងឺកាមរោគ ) |

| | |
|---|---|
| UNAIDS | United Nations Joint Program on AIDS ( កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍របស់អង្គការសហប្រជាជាតិ ) |
| USAID | United State Agency for International Development ( ភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីការអភិវឌ្ឍអន្តរជាតិ ) |
| VCCT | Voluntary Confidential Counseling and Testing ( ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ ) |

# បញ្ជីរូបភាព


១. រូបភាពទី១: លទ្ធផលសម្រេចបាន នៅត្រឹមត្រីមាសទី៣ ឆ្នាំ២០១៨ ធៀបនឹងគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០២០.......................................................................................១១

២. រូបភាពទី២: និន្នាការចំនួនទីកន្លែងផ្តល់សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ដែលបានទទួលសេវាគិតពីឆ្នាំ២០០១ មកត្រឹម ត្រីមាសទី៤ឆ្នាំ២០១៨.......................................................................................១២

៣. រូបភាពទី៣: និន្នាការចំនួនអ្នកផ្ទុកមេរោគអេដស៍កុមារ និងមនុស្សពេញវ័យដែលបាន ទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីត្រីមាសទី១ ឆ្នាំ២០១៤ មកត្រឹមត្រីមាសទី៤ឆ្នាំ២០១៨.......................................................................................១២

៤. រូបភាពទី៤: និន្នាការនៃអត្រាធ្វើតេស្តរកមេរោគអេដស៍ ក្នុងចំណោមស្ត្រីមានផ្ទៃពោះ ពីឆ្នាំ២០០៧-២០១៧ ( HIV Testing for Pregnant Women )......................១៣

៥. រូបភាពទី៥: របាយនិន្នាការអត្រាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួល ឱសថប្រឆាំងមេរោគអេដស៍ទៅតាមឆ្នាំនីមួយៗពី២០០៧-២០១៧ ( Pregnant Women on ART by Year )..........................................................១៤

៦. រូបភាពទី៦: អត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូនទៅតាមឆ្នាំនីមួយៗ( Mother-to-Child Transmission Rate )..............................................................១៤

# ១. សេចក្ដីផ្ដើម

## ១.១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានបេសកកម្មរបស់ខ្លួនក្នុងការដឹកនាំគ្រប់គ្រង និងសម្របសម្រួល ត្រួតពិនិត្យ និងវាយតម្លៃនៃការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ការដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យ វាយតម្លៃខាងលើយោងតាម ១) ច្បាប់ស្ដីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ២) គម្រោងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ (២០១៥-២០២០) ៣) គម្រោងផែនការសកម្មភាពឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៨ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៤) គោលនយោបាយប្រាំពីរចំណុចក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ តាមលិខិតលេខ២០៤៨ ស.ជ.ណ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៣ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងសេចក្ដីសម្រេចចិត្តនានានៃកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ៥) សេចក្ដីសម្រេចចិត្តរបស់អង្គការសហប្រជាជាតិក្នុងយុទ្ធសាស្ត្រ សូន្យ បី ដោយប្រកាន់នូវគោលការណ៍ បី មួយ ក្នុងការគាំទ្រដល់ការឆ្លើយតបទូលំទូលាយ និងពហុវិស័យ និងគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០២០ តាមរយៈការប្រើប្រាស់រចនាសម្ព័ន្ធដឹកនាំគ្រប់គ្រង និងសម្របសម្រួលជាតិតែមួយ ផែនការយុទ្ធសាស្ត្រជាតិតែមួយ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃជាតិតែមួយ។

## ១.២. គម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៨

យោងតាមព័ត៌មានដែលទទួលបានពីការពិនិត្យឡើងវិញនូវវឌ្ឍនភាព ប្រសិទ្ធភាព និងសមិទ្ធផលនៃការអនុវត្តផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ឆ្នាំ២០១៨ កន្លងមក គម្លាតនៃការឆ្លើយតប និងអនុសាសន៍ដែលមានលក្ខណៈអនុវត្តជាក់ស្តែងបានយកមកប្រើប្រាស់ក្នុងការរៀបចំជាផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៨ ដោយប្រើប្រាស់យុទ្ធសាស្ត្រជាតិទាំង៦ជាគោលដូចខាងក្រោម៖

**១.២.១.** យុទ្ធសាស្ត្រទី១: ការបង្ការការចម្លងមេរោគអេដស៍ថ្មី

**១.២.២.** យុទ្ធសាស្ត្រទី២: ការព្យាបាល ថែទាំ និងគាំទ្រអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍

**១.២.៣.** យុទ្ធសាស្ត្រទី៣: ការកាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និងជំងឺអេដស៍

**១.២.៤.** យុទ្ធសាស្ត្រទី៤: ការដឹកនាំសម្របសម្រួលភាគីពាក់ព័ន្ធ ការកៀរគរ និងបែងចែកធនធាន

**១.២.៥.** យុទ្ធសាស្ត្រទី៥: ការបង្កើតបរិយាកាសគាំទ្រ និងគោលនយោបាយ

**១.២.៦.** យុទ្ធសាស្ត្រទី៦: បង្កើនប្រព័ន្ធតាមដាន និងវាយតម្លៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តែមួយ(ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ៥ទៀត)

# ២. គោលបំណង និងកម្មវត្ថុ

## ២.១. គោលបំណង

ចងក្រង និងផ្សព្វផ្សាយរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រចាំឆ្នាំ២០១៨ និងដើម្បីប្រើប្រាស់ជាឯកសារ ក្នុងការវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគម្រោងផែនការសកម្មភាពប្រចាំឆ្នាំ២០១៨ ផងដែរ។ លើសពីនេះរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលប្រចាំឆ្នាំ២០១៨នេះ នឹងប្រើប្រាស់ជាឯកសារយោងក្នុងការកែលំអការរៀបចំផែនការសកម្មភាពទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឆ្នាំ២០១៩ ឱ្យកាន់តែប្រសើរថែមទៀត ។

## ២.២. កម្មវត្ថុ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ ការរៀបចំរបាយការណ៍នេះ មានកម្មវត្ថុមួយចំនួនដូចខាងក្រោម៖

ក. ប្រមូល សម្អាត និងវិភាគទិន្នន័យដែលប្រមូលបានពីប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃជាតិ ឱ្យក្លាយទៅជាព័ត៌មានវិទ្យាសាស្ត្រពិត និងប្រកបដោយទំនុកចិត្តខ្ពស់។

ខ. រៀបចំព័ត៌មានឱ្យទៅជាតារាង ឬរូបភាពដោយមានការបកស្រាយច្បាស់លាស់ពីខ្លឹមសាររបស់វាឱ្យបានត្រឹមត្រូវ ។

គ. រៀបចំការសម្របសម្រួល និងស្វែងរកការឯកភាពរួមគ្នារវាងស្ថាប័ន និងបុគ្គលទាំងអស់ដែលទទួលខុសត្រូវក្នុងការរៀបចំរបាយការណ៍ទៅលើព័ត៌មានដែលបានបកស្រាយនៅក្នុងរបាយការណ៍នេះ ។

# ៣. វិធីសាស្ត្រ

របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលឆ្នាំ២០១៨ ត្រូវបានរៀបចំឡើងដោយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដោយប្រើប្រាស់នូវទម្រង់ប្រមូលទិន្នន័យជាតិ និងប្រព័ន្ធត្រួតពិនិត្យជាតិមួយ ដែលចាប់យកនូវទិន្នន័យទាំងអស់ពីការអនុវត្តផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ពីគ្រប់ស្ថាប័នជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនៅទូទាំងប្រទេស ដែលបានផ្ញើមកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

បន្ទាប់ពីទទួលបាននូវទិន្នន័យជាតិរួចហើយ វិធីសាស្ត្រគ្រប់គ្រងទិន្នន័យបានប្រើប្រាស់ក្នុងការសម្អាត ផ្ទៀងផ្ទាត់ និងវិភាគទិន្នន័យ បន្តដោយវិធីសាស្ត្ររៀបចំព័ត៌មានឱ្យទៅជាតារាង ឬរូបភាព និងបញ្ចប់ដោយការបកស្រាយ។ វិធីសាស្ត្រដែលប្រើប្រាស់ចុងក្រោយបង្អស់គឺវិធីសាស្ត្រចងក្រងរបាយការណ៍ ដោយរៀបចំការសរសេរជាសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆ្នាំ២០១៨ ។

បន្ទាប់ពីបានរៀបចំនូវសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលក្នុងការឆ្លើយតបទូលំទូលាយ និងពហុវិស័យឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆ្នាំ២០១៨ចប់សព្វគ្រប់ហើយនាយកដ្ឋានផែនការ ត្រួតពិនិត្យ វាយតម្លៃ និងស្រាវជ្រាវបានផ្ញើជូននាយកដ្ឋានទាំងអស់របស់អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដើម្បីផ្តល់យោបល់កែលំអ បន្ទាប់មកសេចក្តីព្រាងរបាយការណ៍នេះក៏បានយកមករៀបចំកែសម្រួលទៅតាមការផ្តល់យោបល់ឱ្យទៅជាសេចក្តីព្រាងរបាយការណ៍លើកទី២ ដើម្បីដាក់ជូនទៅសុំមតិយោបល់បន្តពីថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្នុងគោលបំណងបំពេញបន្ថែមនូវគម្លាតព័ត៌មាន និងដើម្បីកែសម្រួលរាល់ចំណុចខ្វះខាតនានាពាក់ព័ន្ធជាសំខាន់ទៅលើសុក្រឹតភាព និងជំនឿទុកចិត្តទៅលើព័ត៌មានទាំងនោះ។ ក្រោយពីការកែសម្រួលរបាយការណ៍រួចហើយ នឹងដាក់ជូនសុំការសម្រេចពីថ្នាក់ដឹកនាំអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ដើម្បីសម្រេច និងធ្វើការផ្សព្វផ្សាយជូនដល់សមាជិក សមាជិកា របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

## ៤. វឌ្ឍនភាព និងសមិទ្ធផល

សម្រាប់ឆ្នាំ២០១៨ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទទួលបានទិន្នន័យពីស្ថាប័នដែលជាសមាជិកមានការយឺតយ៉ាវ មិនបានគ្រប់ស្ថាប័ន និងដៃគូអភិវឌ្ឍទាំងអស់ទេ។ ម្យ៉ាងទៀតក្រសួង ស្ថាប័នមួយចំនួនពុំទាន់មានសកម្មភាព និងទិន្នន័យទាក់ទងនឹងសកម្មភាពឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅឡើយ។

### ៤.១. យុទ្ធសាស្ត្រទី១: ផ្តួចផ្តើមការបង្ការមេរោគអេដស៍ដោយផ្តោតលើអន្តរាគមន៍ដែលបង្កើនការគ្របដណ្តប់ដែលមានគុណភាព និងប្រសិទ្ធភាពនៃអន្តរាគមន៍បង្ការ

**១. យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងទិវានៃក្តីស្រឡាញ់**

អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសហការជាមួយអង្គការសង្គមស៊ីវិល បើកយុទ្ធនាការផ្សព្វផ្សាយអប់រំ ស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ជូនដល់ប្រជាជនទូទៅ និងយុវជន នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ ក្រោមអធិបតីភាពឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

**២. ពិធីចែកស្រោមអនាម័យចំនួន៥០ម៉ឺនស្រោម**

អ.ជ.ប.ជ.អ បានបែងចែកស្រោមអនាម័យចំនួន៥០ម៉ឺនស្រោមជូនដល់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានី ខេត្ត និងអគ្គបញ្ជាការកងយោធពលខេមរភូមិន្ទនាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨។

## ៣. ក្រសួងការពារជាតិ

យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមកងកម្លាំងប្រដាប់អាវុធ។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ សហការជាមួយអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ និងអង្គការAHF បានរៀបចំសិក្ខាសាលាស្តីពីបច្ចុប្បន្នភាពនៃការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងបញ្ហាប្រឈមរបស់យុវវ័យនៅកម្ពុជាដល់នាយទាហាន នាយទាហានរងនៅខេត្តកណ្តាល ក្រុងព្រះសីហនុ កំពង់ស្ពឺ កំពង់ឆ្នាំង និងនិស្សិតវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាល សរុបទាំងអស់ចំនួន ១២៩០ នាក់។
- បានបញ្ជ្រាបកម្មវិធីពីមេរោគអេដស៍/ជំងឺអេដស៍ ក្នុងកម្មវិធីអប់រំចិត្តសាស្ត្រ កម្មវិធីអប់រំជំងឺគ្រុនចាញ់ ព្រមទាំងកម្មវិធីផ្សេងៗទៀត ចំនួន២៨អង្គភាព នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ដែលមានអ្នកចូលរួមសរុប ៩៦៨៧នាក់។
- បានសហការជាមួយអង្គការ AHF ចុះធ្វើការអប់រំផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់ តាមរយៈរថយន្តចល័ត បានចំនួន ២៧អង្គភាព មានអ្នកចូលរួមធ្វើតេស្តឈាមសរុប៣៧៩០នាក់ (ទ័ពមានចំនួន៣២៤៤នាក់ គ្រួសារទ័ព ៥៤៦នាក់ លទ្ធផលតេស្តវិជ្ជមាន១៣នាក់)។
- បានបញ្ចូលសកម្មភាពអប់រំ ស្តីពីជំងឺអេដស៍ កាមរោគ គ្រុនចាញ់ គ្រុនឈាម គ្រឿងញៀន គ្រឿងស្រវឹង ក្នុងកម្មវិធីចុះអភិបាលកិច្ច នៅសាលានាយទាហានសកម្ម(ត្នាតពង) បានចំនួន៣លើក ដែលមានអ្នកចូលរួមសរុបចំនួន៣២០នាក់ ។
- ទីចាត់ការសុខាភិបាលអគ្គបញ្ជាការដ្ឋានបានរៀបចំវគ្គបណ្តុះបណ្តាល អប់រំ ផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ និងមេរោគស្វាយដោយស្ម័គ្រចិត្តដល់សិក្ខាកាម ចំនួន ២៥នាក់ (សហការជាមួយអង្គការ AHF) ។
- បានអប់រំ ផ្សព្វផ្សាយពីជំងឺអេដស៍ និងការប្រឈមរបស់យុវវ័យបានចំនួន៥វគ្គ (កងឯកភាពស្ថាប័នចំណុះអគ្គបញ្ជាការដ្ឋាននៅបញ្ជាការដ្ឋានទ័ពជើងទឹក បញ្ជាការមូលដ្ឋានសមុទ្រ សាលាហ្វឹកហ្វឺនឯកទេសបំភ័ន្តអក្ខរៈ) ដែលមាននាយទាហាន ពលទាហានចូលរួមសរុបចំនួន ២២២០នាក់។
- ធ្វើតេស្តឈាមរកមេរោគអេដស៍បានចំនួន ៦អង្គភាព៖ មូលដ្ឋានសមុទ្រ កងពលតូចអន្តរាគមន៍លេខ១ បញ្ជាការដ្ឋានកងទ័ពជើងអាកាស កងពលតូចទ័ពពិសេស ឆ័ត្រយោង ៩១១ សាលានាយទាហានសកម្ម បញ្ជាការដ្ឋានកាំភ្លើងធំ មានចំនួន២៣៧៣នាក់។
- ការងារអប់រំផ្សព្វផ្សាយ បច្ចុប្បន្នភាពទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងការប្រឈមរបស់យុវវ័យ នៃកងយោធពលខេមរភូមិន្ទដោយមានអ្នកចូលរួមចំនួន ២១៨៥នាក់។

### ៤. យុទ្ធនាការផ្សព្វផ្សាយចំណេះដឹងស្តីពីមេរោគអេដស៍ និងជំងឺអេដស៍ក្នុងចំណោមមន្ត្រីរាជការ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងបរិស្ថាន សហការជាមួយអគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានរៀបចំផ្សព្វផ្សាយចំណេះដឹងស្តីពី "ការរីករាលដាលនៃការឆ្លងមេរោគអេដស៍ និងជំងឺអេដស៍" ជូនដល់មន្ត្រីរាជការនៅតាមក្រសួងទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

### ៥. យុទ្ធនាការផ្សព្វផ្សាយពីវិធីបង្ការមេរោគអេដស៍ក្នុងព្រះរាជពិធីបុណ្យអុំទូក

យុទ្ធនាការផ្សព្វផ្សាយពីវិធីបង្ការមេរោគអេដស៍រយៈពេល ៣ថ្ងៃ ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ដោយមានការប្រគុំតន្ត្រី ផ្តល់សារអប់រំសំណួរចម្លើយដល់អ្នកចូលរួមពីការបង្ការមេរោគអេដស៍ និងចែកស្រោម អនាម័យដល់អ្នកដែលបានចូលរួមពិធីយ៉ាងច្រើនកុះករ។

### ៦. ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៨

អ.ជ.ប.ជ.អ បានរៀបចំទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ ១ធ្នូ ឆ្នាំ២០១៨ ក្រោមអធិបតីភាពឯកឧត្តម យឹម ឆៃលី ឧបនាយករដ្ឋមន្ត្រី ក្នុងប្រធានបទយើងរួមគ្នាបញ្ចប់បញ្ហាអេដស៍នៅឆ្នាំ២០២៥ និងយុទ្ធនាការផ្សព្វផ្សាយការបង្ការការឆ្លងមេរោគអេដស៍តាមរយៈការប្រគុំតន្ត្រីដ៏ធំមួយនៅមជ្ឈមណ្ឌលកំសាន្តកោះពេជ្រនៅថ្ងៃទី១ ធ្នូ ឆ្នាំ២០១៨ និងនៅទីលានប្រជាធិបតេយ្យដោយមានការចូលរួមពីយុវជន យុវនារីក្នុងការចូលរួមឆ្លើយសំណួរទាក់ទងនឹងការបង្ការមេរោគអេដស៍។

### ៧. ក្រសួងអប់រំ

ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមយុវវ័យ

- បានអភិវឌ្ឍខ្លឹមសារ កម្មវិធីសិក្សាលម្អិត (Corps Syllabus)ស្តង់ដារកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ដែលមានមេរៀនអប់រំបង្ការមេរោគអេដស៍ និងគ្រឿងញៀន នៅក្នុងមុខវិជ្ជាអប់រំសុខភាពពីថ្នាក់ទី៥ ដល់ទី១២ ស្របតាមក្របខណ្ឌកម្មវិធីសិក្សាថ្មីឆ្នាំ ២០១៦- ២០២៥ សម្រាប់ការអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស។
- បានបើកវគ្គផ្សព្វផ្សាយស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងសុខភាពផ្លូវភេទ គ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្រោះថ្នាក់ចរាចរ និងបញ្ហាសង្គមមួយចំនួនទៀតដល់លោកគ្រូ អ្នកគ្រូ និងសិស្ស ថ្នាក់ទី ១១ ១២ នៅវិទ្យាល័យ ៣ ក្នុងស្រុកកងមាស ខេត្តកំពង់ចាម មានអ្នកចូលរួម ២១៥៧នាក់។
- បានចេញសេចក្តីណែនាំដល់គ្រប់គ្រឹះស្ថានមធ្យមសិក្សា នៅទូទាំងប្រទេសត្រូវធ្វើការអប់រំពីការបង្ការមេរោគអេដស៍ ជំងឺអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ គ្រោះថ្នាក់ចរាចរ និងអំពើហិង្សាក្នុងគ្រួសារ ការអប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀននៅក្នុង"ទិវាជាតិ-អន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ២៦ មិថុនា ២០១៨" នៅក្នុងក្របខណ្ឌសាលារបស់ខ្លួន។ ដែលមានបុគ្គលិកអប់រំ និងសិស្សានុសិស្សចូលរួម សរុបចំនួន ១.៨១៦.១៤១ នាក់ ស្រី៨៩១.៩៥៨នាក់។

- បានបើកវគ្គផ្សព្វផ្សាយស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងសុខភាពផ្លូវភេទ គ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ គ្រោះថ្នាក់ចរាចរ និងអំពើហិង្សាក្នុងគ្រួសារដល់មន្ត្រីក្រសួងអបរំ អាជ្ញាធរដែនដី លោកគ្រូ អ្នកគ្រូ គរុសិស្ស និស្សិត និងសិស្សានុសិស្សនៅ៖
    - សាខាសាកលវិទ្យាល័យបៀលប្រាយ ខេត្តព្រះសីហនុ ចំនួន៤០០នាក់ ។
    - សាលាគរុកោសល្យនិងវិក្រិតិការ ខេត្តកំពង់ចាម ចំនួន២០៥នាក់ ។
    - នៅសាកលវិទ្យាល័យបាត់ដំបង ចំនួន៤២៣នាក់ ។

## ៨. ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនចល័ត

- ផ្តល់ការអប់រំស្តីពីការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ គ្រឿងញៀន សុខភាពបន្តពូជ និងការប្រើប្រាស់ស្រោមអនាម័យ ដល់ពលករត្រៀមទៅប្រទេសកូរ៉េបានចំនួន ២០១៣នាក់ ស្ត្រី ៨១៧នាក់។
- ចុះតាមដាន និងវាយតម្លៃការអនុវត្តប្រកាស ០៨៦ ស្តីពីការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន និងប្រកាសលេខ ១៩៤ ស្តីពីលក្ខខណ្ឌការងារ វិធានអនាម័យ សន្តិសុខការងារ នៅតាមសហគ្រាស គ្រឹះស្ថាន នៅខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តបន្ទាយមានជ័យ ខេត្តក្រចេះ ខេត្តរតនគិរី ខេត្តព្រះវិហារ ខេត្តមណ្ឌលគិរី ខេត្តស្ទឹងត្រែង ខេត្តព្រៃវែង ខេត្តកំពត និងខេត្តកែប។
- សិក្ខាសាលាផ្សព្វផ្សាយប្រកាសលេខ ១៩៤ ស្តីពីលក្ខខណ្ឌការងារ វិធានការអនាម័យ និងសន្តិសុខការងារនៅតាមសហគ្រាស គ្រឹះស្ថាន ដល់កម្មករនិយោជិតផ្នែកសេវាកម្សាន្ត បានចំនួន៦វគ្គនៅខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបន្ទាយមានជ័យ ដែលមានអ្នកចូលរួមចំនួនសរុប ១២០នាក់ ស្រី៣៩នាក់។
- ចុះជំរុញការអនុវត្តប្រកាសលេខ ០៨៦ ស្តីពីការបង្កើត គណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន តាមរយៈក្រុមអធិការកិច្ចការងារ មានរោងចក្រសហគ្រាសបង្កើតគណៈកម្មការអេដស៍ថ្មីចំនួន៥៧។
- រៀបចំកិច្ចប្រជុំគណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង ដើម្បីពិនិត្យឡើងវិញនូវវឌ្ឍនភាព និងសមិទ្ធផលឆ្នាំ២០១៨ និងត្រៀមរៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ ២០១៩។

## ៩. ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "មន្ត្រីរាជការ"

- បានប្រជុំផ្សព្វផ្សាយចំណេះដឹងស្តីពីការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ នៅមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តណ្តាល កំពង់ឆ្នាំង កំពង់ចាម និងកំពង់ធំ។

- បានចុះផ្សព្វផ្សាយការងារអេដស៍ ដល់សិប្បកម្មផលិតទឹកសុទ្ធក្នុងខេត្តចំនួន៧ មានខេត្ត ពោធិ៍សាត់ បាត់ដំបង សៀមរាប កោះកុង ព្រះសីហនុ មណ្ឌលគិរី និងរតនគិរី។
- បានប្រជុំផ្សព្វផ្សាយ នៅទីស្តីការក្រសួង ដើម្បីក្រើនរំលឹកឆ្លើយតបទៅនឹងការរាលដាល មេរោគអេដស៍ និងជំងឺអេដស៍បាន ចំនួន១លើក។

## ១០. ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "ប្រជាជនទូទៅ"

- បានធ្វើការណែនាំដល់អង្គភាពក្រោមឱវាទក្រសួងដែលមានគេហទំព័រឱ្យផ្សព្វផ្សាយសារអប់រំ ជាប្រចាំទាំងបញ្ហាអេដស៍ គ្រឿងញៀន និងគ្រោះថ្នាក់ចរាចរណ៍នៅលើគេហទំព័ររបស់ខ្លួន។
- បានប្រារព្ធសិក្ខាសាលាក្រោមប្រធានបទ " យើងនាំគ្នាចូលរួមប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីបញ្ចប់អេដស៍នៅឆ្នាំ២០២៥" ដែលមានអ្នកចូលរួមចំនួន ២៩៣នាក់។
- បានអនុញ្ញាតឲ្យប្រើប្រាស់ប្រព័ន្ធលេខទូរស័ព្ទខ្លី៤ខ្ទង់ (១២៩៥) សម្រាប់ កម្មវិធីអប់រំអំពី បញ្ហាអេដស៍ សុខភាពបន្តពូជ សុខភាពផ្លូវភេទ ជាសម្លេងតាមទូរស័ព្ទដោយឥតគិតថ្លៃ (សហការជាមួយអង្គការ FHI360) និង One World ដែលបានប្រើលេខ"១២៩៣" សម្រាប់ ផ្ញើសារអក្សរតាមទូរស័ព្ទដៃជាសំណួរ/ចម្លើយរវាងប្រជាពលរដ្ឋ និងក្រុមប្រឹក្សាជំនាញ។
- បានជំរុញការផ្សព្វផ្សាយអប់រំអំពីបញ្ហាអេដស៍ នៅក្នុងព្រឹត្តិប័ត្រប្រចាំត្រីមាស ក្នុងគេហទំព័រ របស់ក្រសួង និងក្នុងគេហទំព័ររបស់អង្គភាពក្រោមឱវាទក្រសួង។
- បានចូលរួមអន្តរាគមន៍ និងសហការជាមួយនិយ័តករទូរគមនាគមន៍កម្ពុជាស្នើទៅប្រតិបត្តិករ ទូរស័ព្ទចល័តទាំងអស់ សរសេរនិងបញ្ជូនសារ SMS ខ្លីៗទៅកាន់ទូរស័ព្ទដៃនៃអតិថិជន រៀងៗខ្លួន ដើម្បីផ្សព្វផ្សាយអប់រំអំពីបញ្ហាអេដស៍ អំពីបញ្ហាគ្រឿងញៀន នាឱកាសបុណ្យ អុំទូក បណ្តែតប្រទីប អកអំបុក សំពះព្រះខែ និងទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១៨។

## ១១. ក្រសួងព័ត៌មាន

ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម "មន្ត្រីរាជការក្រសួង" និងប្រជាជនទូទៅ

- បានបញ្ចូល និងបញ្ជ្រាបសារអប់រំស្តីពីការបង្ការការចម្លងមេរោគអេដស៍ និងការកាត់បន្ថយ ការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ នៅក្នុងសន្និបាតបូកសរុប សមិទ្ធផលវិស័យព័ត៌មាន និងសោតទស្សន៍ ដែលមានសមាជិកចូលរួមចំនួន ៤០០នាក់។
- បានរៀបចំវេទិកាតុមូល ដោយមានការបកស្រាយសំណួររបស់ប្រិយមិត្តអ្នកស្តាប់ជារៀងរាល់ ឆ្នាំសម្រាប់ទិវាពិភពលោកប្រយុទ្ធនឹងជំងឺអេដស៍១ធ្នូ និងនៅក្នុងពិធីបុណ្យជាតិសំខាន់ៗ ដូចជាបុណ្យអុំទូក អកអំបុក សំពះព្រះខែ តាមវិទ្យុជាតិកម្ពុជា(AM 918 khz)។

## ១២. ក្រសួងសាធារណៈការ និងដឹកជញ្ជូន

ការឆ្លើយតបមេរោគអេដស៍ ក្នុងវិស័យសាធារណៈការ និងដឹកជញ្ជូន

- បានបញ្ច្រាបការអប់រំស្តីពីការបង្កាមេរោគអេដស៍ និងជំងឺអេដស៍តាមកម្មវិធីប្រជុំ ក្នុងពេលប្រឡងយក ប័ណ្ណបើកបរ កម្មវិធីមួកសុវត្ថិភាពដល់បុគ្គលិកមន្ត្រីជាប់កិច្ចសន្យា កម្មករវែចទាំផ្លូវ សិស្សវិទ្យាល័យ នៅតាមមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តចំនួន៨ខេត្ត ដោយមានអ្នកចូលរួមចំនួន៧៦៧០នាក់៖
  ១. ខេត្តព្រៃវែង ៥លើក មានអ្នកចូលរួម សរុប៤០៩នាក់។
  ២. ខេត្តព្រះវិហារ ៧លើក មានអ្នកចូលរួម សរុប១៣១៤នាក់។
  ៣. ខេត្តក្រចេះ ៣លើក មានអ្នកចូលរួម សរុប១០៧៥នាក់។
  ៤. ខេត្តស្ទឹងត្រែង ៧លើក មានអ្នកចូលរួម សរុប១៥៤១នាក់។
  ៥. ខេត្តឧត្តរមានជ័យ ១លើក មានអ្នកចូលរួម សរុប៦៤៦នាក់។
  ៦. ខេត្តកែប៤លើក មានអ្នកចូលរួម សរុប៩៨០នាក់។
  ៧. ខេត្តបាត់ដំបង១លើក មានអ្នកចូលរួម សរុប៨៨៧នាក់។
  ៨. ខេត្តកំពង់ចាម៥លើក មានអ្នកចូលរួម សរុប៨១៥នាក់ ។

## ១៣. ក្រសួងកិច្ចការនារី

ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោមស្ត្រី និងក្មេងស្រី

- វគ្គបណ្តុះបណ្តាលស្តីពីទំនាក់ទំនងមាតា និងយុវតី យេនឌ័រ សុខភាពបន្តពូជ សុខភាពផ្លូវភេទ ជំងឺកាមរោគ ជំងឺអេដស៍ ដល់មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក និងអ្នកទទួលបន្ទុកកិច្ចការនារីឃុំ សង្កាត់ចំនួន២លើក នៅខេត្តសៀមរាប និងខេត្តព្រៃវែង ដែលមានអ្នកចូលរួមសរុប៨០នាក់ (ស្ត្រី ៧៥ នាក់) ដោយប្រើប្រាស់ថវិកាជាតិ។
- បានរៀបចំបញ្ចូលការបង្ការការចម្លងមេរោគអេដស៍ និងជំងឺអេដស៍ទៅក្នុងគម្រោងផែនការសកម្មភាព និងថវិកាជាតិ ឆ្នាំ២០១៩ ដោយមានជាវគ្គបណ្តុះបណ្តាលចំនួន៣លើក និងវេទិកាអប់រំចំនួន៥ដង ទៅដល់មន្ទីរកិច្ចការនារីខេត្ត ការិយាល័យកិច្ចការនារីស្រុក អ្នកទទួលបន្ទុកកិច្ចការនារីឃុំ សង្កាត់ និងប្រជាជនទូទៅ។

## ១៤. ក្រសួងទេសចរណ៍

ការបង្ការការចម្លងមេរោគអេដស៍ក្នុងចំណោម ប្រតិបត្តិករទេសចរណ៍

- បានរៀបចំបញ្ច្រាបផែនការថវិកាជាតិ សម្រាប់ចំណាយលើសកម្មភាពការងារទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ ឆ្នាំ២០១៨។
- បានបញ្ចូលសារអប់រំមេរោគអេដស៍ ជំងឺអេដស៍ ដល់វគ្គបណ្តុះបណ្តាលប្រតិបត្តិករទេសចរណ៍ចំនួន ៨០នាក់ នៅខេត្តតាកែវ ។
- សិក្ខាសាលាការបង្ការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងវិស័យទេសចរណ៍ នៅខេត្តកំពង់ធំ ខេត្តតាកែវ និងខេត្តកំពង់ស្ពឺ ដែលសហការជាមួយអាជ្ញាធរជាតិ

ប្រយុទ្ធនឹងជំងឺអេដស៍ និងគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ខេត្ត ដោយមានអ្នកចូលរួមសរុបចំនួន ១៨០នាក់។

## ១៥. ក្រសួងពាណិជ្ជកម្ម

- បានរៀបចំផែនការថវិកាសម្រាប់ចំណាយលើសកម្មភាពការងារទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ឆ្នាំ២០១៨ និងឆ្នាំ២០១៩-២០២១ ។
- បានបញ្ចូលសារអប់រំមេរោគអេដស៍/ជំងឺអេដស៍ ដល់មន្ត្រីក្រសួងពាណិជ្ជកម្ម ចំនួន២លើក ដោយមានអ្នកចូលរួមចំនួន ៨០នាក់ ។
- បានបញ្ជ្រាបការងារអប់រំ ផ្សព្វផ្សាយពីការទប់ស្កាត់ការរាលដាលមេរោគអេដស៍ តាមកិច្ចប្រជុំគោលនយោបាយ សិក្ខាសាលា និងការប្រជុំប្រចាំខែរបស់ក្រសួង ។

## ១៦. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានរៀបចំទិវាគ្រួសារដែលមានគ្រួសារគំរូ ចំនួន៤៥០គ្រួសារ ក្នុងនោះមានគ្រួសារដែលមានផ្ទុកមេរោគអេដស៍៥០គ្រួសារ ។
- ចែកអំណោយដល់គ្រួសាររងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍ចំនួន២៦៩នាក់ នៅភូមិរកា ឃុំរកា ស្រុកសង្កែ ខេត្តបាត់ដំបង។
- បានផ្តល់អាហារូបត្ថម្ភដល់កុមាររងគ្រោះ និងងាយរងគ្រោះដោយសារមេរោគអេដស៍ និងជំងឺអេដស៍នៅមន្ទីរពេទ្យកុមារអង្គរចំនួន៨កេះ ។
- បានលើកគម្រោងសកម្មភាព និងថវិកាជាតិដោយបញ្ជ្រាបទៅក្នុងផែនការក្រសួង
- បានរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារឆមាសទី១ និងលើកទិសដៅបន្តរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង មានអ្នកចូលរួមចំនួន៥១នាក់។
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយចំណេះដឹងស្តីពីជំងឺកាមរោគ និងមេរោគអេដស៍ និងជំងឺអេដស៍ នៅមណ្ឌលសង្គមកិច្ចព្រៃស្ពឺដោយមានអ្នកចូលរួមចំនួន៤២នាក់ ។

## ១៧. ក្រសួងបរិស្ថាន

- បានរៀបចំពិធីអបអរសាទរចូលរួមប្តេជ្ញាបញ្ចប់អេដស៍ត្រឹមឆ្នាំ២០២៥ ក្រោមអធិបតីភាពឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន និងអគ្គលេខាធិកា អ.ជ.ប.ជ.អ និងមន្ត្រីក្រសួងបរិស្ថាន ចំនួន ២៥៦នាក់។
- បានបញ្ជ្រាបការងារអេដស៍ និងយេនឌ័រទៅក្នុងសិក្ខាសាលាផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រក្នុងវិស័យបរិស្ថានឆ្នាំ២០១៦ ដល់២០២០។
- ផ្សព្វផ្សាយការបង្ការមេរោគអេដស៍ និងជំងឺអេដស៍ និងផ្តល់សម្ភារៈមួយចំនួនដូចជាស្រោមអនាម័យ ២១២ប្រអប់ អាវយឺត ៣៩០អាវ និងឯកសារអេដស៍ចំនួន២០០ក្បាលដល់មន្ត្រីឧទ្យានុរក្សនៅតាមរាជធានីខេត្ត។

### ១៨. ក្រសួងរ៉ែ និងថាមពល

- បានរៀបចំផែនការសកម្មភាពប្រយុទ្ធនឹងជំងឺអេដស៍ក្នុងវិស័យរ៉ែ ថាមពល និងប្រេងកាត សម្រាប់ឆ្នាំ២០១៩។
- ធ្វើសិក្ខាសាលាផ្សព្វផ្សាយពីការប្រយុទ្ធទប់ស្កាត់មេរោគអេដស៍ និងជំងឺអេដស៍ដល់មន្ត្រីក្រោមឱវាទក្រសួងដោយមានមានអ្នកចូលរួម ១០២នាក់។

### ១៩. អង្គការ ភី អេស អាយ កម្ពុជា

បង្ការការចម្លងមេរោគអេដស៍តាមរយៈការផ្សព្វផ្សាយ និងចែកចាយ "ស្រោមអនាម័យ"

- បានធ្វើការងារលើកកម្ពស់ទីផ្សារស្រោមអនាម័យ ជំរុញការប្រើប្រាស់ស្រោមអនាម័យដោយបានលក់ស្រោមអនាម័យចំនួន ៧,៩៣០,៨៦០ ក្នុងរយៈពេល៨ខែ ចាប់ពីខែមករា ដល់ខែសីហា ឆ្នាំ២០១៨។

## ៤.២.យុទ្ធសាស្ត្រទី២: បង្កើន និងរក្សាគុណភាព ការគ្រប់ដណ្តប់ និងការរក្សាទុកគ្រប់ជំហានទាំងអស់នៅក្នុងការថែទាំ ព្យាបាលបន្តដោយយកត័ស្តុតាង និងការណែនាំជាមូលដ្ឋាន

### ១. លទ្ធផលពិនិត្យ និងពិគ្រោះជំងឺនៅមន្ទីរពេទ្យយោធភូមិភាគទី៥

មន្ទីរពេទ្យយោធភូមិភាគទី៥ សហការជាមួយអង្គការAHF បានផ្តល់សេវាពិនិត្យ និងពិគ្រោះជំងឺ (សេវាកម្ម ART) ក្នុងរយៈពេល៥ខែ ដើមឆ្នាំ២០១៨ ដោយមានអ្នកមកធ្វើតេស្តឈាម (VCCT) សរុប ៩៤០នាក់ (ប្រុស១៩០នាក់ ស្រី ៨១០នាក់) អ្នកបានមកទទួលឱសថ ARV សរុប ៧៩៨នាក់ (ប្រុស ៤៦៩នាក់ ស្រី ៣២៩នាក់) ។ ដោយឡែក អ្នកដែលមកទទួលសេវាព្យាបាលជំងឺឱកាសនិយម (OI) មានចំនួន១៩នាក់ (ប្រុស១៣នាក់ ស្រី ៦នាក់)។

### ២. លទ្ធផលការព្យាបាលអ្នកជំងឺអេដស៍នៅមន្ទីរពេទ្យព្រះកេតុមាលា

ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ មន្ទីរពេទ្យព្រះកេតុមាលាបានទទួលការព្យាបាលអ្នកផ្ទុកមេរោគអេដស៍ដោយឱសថ ARV សរុប ១០៩៧នាក់ ក្នុងនោះប្រុស ៥៦៥នាក់ ស្រី៥៣២នាក់ ។

រូបភាពទី១: លទ្ធផលសម្រេចបាននៅត្រឹមត្រីមាសទី៣ ឆ្នាំ២០១៨ ធៀបនឹងគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០២០




**៣.** យោងតាមរបាយការណ៍ត្រីមាសទី៣ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគបានបង្ហាញថា មានការកើនឡើងនូវលទ្ធផល នៃអ្នកផ្ទុកមេរោគអេដស៍ដែលបានដឹងពីស្ថានភាពរបស់ខ្លួនពី ៧៩% ទៅ៨៦% និងអត្រាអ្នកទទួលឱសថប្រឆាំងមេរោគអេដស៍ដែលមានប្រសិទ្ធភាពពី ៦៤% ទៅ៨០% នៅក្នុងឆ្នាំ២០១៥ និងឆ្នាំ២០១៧ ។ បើធៀបនឹងគោលដៅ ៩០-៩០-៩០ នៅឆ្នាំ២០២០ អត្រាអ្នកដឹងថាផ្ទុកមេរោគអេដស៍បានទទួលឱសថប្រឆាំងមេរោគអេដស៍បានសម្រេចរហូតដល់៩៨% ក្នុងឆ្នាំ២០១៧ ដែលកើនពី ៧៥% ក្នុងឆ្នាំ២០១៥។ ( រូបភាពទី១ )

រូបភាពទី២: **និន្នាការចំនួនទីកន្លែងផ្តល់សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ និងអ្នកផ្ទុកមេរោគអេដស៍ដែលបានទទួលសេវាគិតពីឆ្នាំ២០០១ មកត្រឹមត្រីមាសទី៤ ឆ្នាំ២០១៨**




៤. គិតត្រឹមត្រីមាសទី៤ ឆ្នាំ២០១៨ សេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ មានចំនួន៦៨កន្លែង មានចំនួនអ្នកជំងឺសកម្មសរុបដែលកំពុងទទួលបានការព្យាបាលដោយ ART ចំនួន ៥៩៨៣៧នាក់ ក្នុងនោះមាន ៥៦៧២៦នាក់ជាមនុស្សពេញវ័យ និង៣១១១នាក់ ជាកុមារ (រូបភាពទី២ និងទី៣)។

រូបភាពទី៣: **និន្នាការចំនួនអ្នកផ្ទុកមេរោគអេដស៍កុមារ និងមនុស្សពេញវ័យដែលបានទទួលសេវាព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ពីត្រីមាសទី១ឆ្នាំ២០១៤ មកត្រឹមត្រីមាសទី៤ឆ្នាំ២០១៨**



## ៥. វឌ្ឍនភាពនៃការលុបបំបាត់ការចម្លងមេរោគអេដស៍ និងស្វាយពីម្តាយទៅកូនឆ្នាំ២០២០

ការធ្វើតេស្តឈាមរកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះ ក្នុងកម្មវិធីលុបបំបាត់ការចម្លងមេរោគអេដស៍ពីម្តាយទៅកូននាឆ្នាំ២០២០ មានការកើនឡើងយ៉ាងឆាប់រហ័សពី១៦% ក្នុងឆ្នាំ២០០៧ ដល់៧៥% ក្នុងឆ្នាំ២០១៥ និង៩៧%ក្នុងឆ្នាំ២០១៧ ក្នុងចំណោមស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យផ្ទៃពោះ និងសម្រាល នៅតាមសេវាសុខាភិបាល(រូបភាពទី៤)។

**៦.** ភាគរយនៃស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍មានការកើនឡើងតាមឆ្នាំជាបន្តបន្ទាប់ចាប់ពី១១%នៅឆ្នាំ២០០៧ ដល់៧៧% នៅឆ្នាំ២០១៤ និង៩៣,៨២% នៅឆ្នាំ២០១៧ (រូបភាពទី៥)។ ចំណែកឯអត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូន មានការធ្លាក់ចុះជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ ពី៣៧% ក្នុងឆ្នាំ២០០៧ នៅត្រឹមតែ១៣%ក្នុងឆ្នាំ២០១៣ និង៦,២% ក្នុងឆ្នាំ២០១៥(រូបភាពទី៦)។

រូបភាពទី៤: **និន្នាការនៃអត្រាធ្វើតេស្តរកមេរោគអេដស៍ក្នុងចំណោមស្ត្រីមានផ្ទៃពោះពីឆ្នាំ២០០៧-២០១៧** (HIV Testing for Pregnant Women)



រូបភាពទី៥: របាយការណ៍និន្នាការអត្រាស្ត្រីមានផ្ទៃពោះផ្ទុកមេរោគអេដស៍ដែលបានទទួលឱសថប្រឆាំងមេរោគអេដស៍ទៅតាមឆ្នាំនីមួយៗពី២០០៧-២០១៧ (Pregnant Women on ART by Year)




រូបភាពទី៦: អត្រាឆ្លងមេរោគអេដស៍ពីម្តាយទៅកូនទៅតាមឆ្នាំនីមួយៗMother-to-Child Transmission Rate



### ៤.៣. យុទ្ធសាស្ត្រទី៣: កាត់បន្ថយផលប៉ះពាល់នៃមេរោគអេដស៍ និងជំងឺអេដស៍តាមរយៈការបង្កើនការគ្រប់ដណ្តប់អន្តរាគមន៍ដែលមានគុណភាព និងប្រសិទ្ធភាព

- រៀបចំកិច្ចប្រជុំក្រុមការងារបង្កើតបរិយាកាសគាំទ្រការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍សម្រាប់ក្រុមប្រជាជនប្រឈមមុខខ្ពស់នៅខេត្តបន្ទាយមានជ័យ។
- បានរៀបចំបញ្ជីឈ្មោះអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍ដើម្បីចងក្រងបញ្ជីគ្រួសារក្រីក្រសម្រាប់សម្ភាសន៍ និងផ្ទៀងផ្ទាត់បញ្ជីឈ្មោះអ្នកជំងឺអេដស៍ផ្ញើទៅក្រសួងផែនការរួមមានខេត្តៈ ឧត្តរមានជ័យ កំពង់ធំ និងរាជធានីភ្នំពេញ ឆ្នាំ២០១៨។
- បានបញ្ចប់និយាមប្រតិបត្តិ ស្តីពីការដាក់បញ្ចូលការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ក្នុងផែនការអភិវឌ្ឍឃុំ-សង្កាត់ និងវិនិយោគឃុំ-សង្កាត់។
- អ.ជ.ប.ជ.អ ពុំបានទទួលរបាយការណ៍ផ្លូវការណាមួយស្តីពីការមាក់ងាយ និងការរើសអើងលើអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ឡើយ។
- អ.ជ.ប.ជ.អ បានសម្របសម្រួលការសិក្សាស្តីពីការមាក់ងាយលើអ្នកផ្ទុកមេរោគអេដស៍លើកទី២ (Stigma Index 2.0) ដោយការគាំទ្រ និងសហការពី NCHADS អង្គការ FHI360, Pop Council, CPN+, HP+, UNAIDS និងស្ថាប័នជាតិពាក់ព័ន្ធ សំខាន់ៗ។ ការសិក្សានេះនឹងត្រូវប្រព្រឹត្តទៅនៅក្នុងខេត្ត រាជធានីចំនួន៦គឺៈ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម និងខេត្តសៀមរាប។
- អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានចុះផ្សព្វផ្សាយនូវនិយាមប្រតិបត្តិសម្រាប់បញ្ចូលកម្មវិធីអេដស៍ទៅក្នុងផែនការអភិវឌ្ឍ និងវិនិយោគ ឃុំ- សង្កាត់នៅខេត្តឧត្តរមានជ័យ។
- បានបញ្ចប់ការងារអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ចំនួន ១៣,៨៥៨នាក់ ក្នុងរាជធានី ខេត្តចំនួន៩ (ស្ទឹងត្រែង ក្រចេះ កំពង់ធំ សៀមរាប កំពង់ចាម ត្បូងឃ្មុំ ឧត្តរមានជ័យ បន្ទាយមានជ័យ និងរាជធានីភ្នំពេញ) ដោយបានផ្តល់ប័ណ្ណក្រីក្រដល់គ្រួសារដែលមានផ្ទុកមេរោគអេដស៍បានចំនួន១៥៩៨គ្រួសារ(១៧%)។

### ៤.៤. យុទ្ធសាស្ត្រទី៤: ការដឹកនាំសម្របសម្រួលភាគីពាក់ព័ន្ធ ការកៀរគរ និងចែករំលែកធនធាន(ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រទាំង៥ទៀត)

ក្នុងការពង្រឹងការដឹកនាំការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការ រាលដាលមេរោគអេដស៍ និងជំងឺអេដស៍នៅទូទាំងប្រទេស អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានប្រើប្រាស់នូវវេទិកាចម្បងមួយចំនួនដូចជា កិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងការចុះប្រាស្រ័យទាក់ទងផ្ទាល់ ជាមួយនឹងគណៈ

កម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រដ្ឋលេខាធិការដ្ឋាន រាជធានីខេត្ត ក្រុង ខណ្ឌ ស្រុក និង សង្កាត់ ឃុំ ដើម្បីត្រួតពិនិត្យនូវវឌ្ឍនភាព បញ្ហាការលំបាក និងផ្តល់ការគាំទ្រជាដំណោះស្រាយ ឬជាអនុសាសន៍។

១. ថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ បានអនុម័តជាគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ។

២. ក្រុមការងាររួមគ្នារវាងរដ្ឋាភិបាល និងដៃគូអភិវឌ្ឍប្រយុទ្ធនឹងជំងឺអេដស៍បានរៀបចំកិច្ចប្រជុំចំនួន២លើក ដោយសម្រេចបាននូវ៖

- បច្ចុប្បន្នភាពស្តីពីការអនុវត្តគម្រោងមូលនិធិសកលឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។
- ឯកភាពលើការរៀបចំផែនការយុទ្ធសាស្ត្រជាតិ សម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ជាពហុវិស័យលើកទី៥។
- ឯកភាពលើរបាយការណ៍វាយតម្លៃ លើការត្រៀមឆ្លើយតបការងារចំពោះមេរោគអេដស៍ និងជំងឺអេដស៍ក្នុងដំណាក់កាលអន្តរកាល។
- ឯកភាពលើការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាព។

**៣. កិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី១**

អ.ជ.ប.ជ.អ បានរៀបចំកិច្ចប្រជុំពេញអង្គលើកទី១ ឆ្នាំ ២០១៨ ដោយបានពិនិត្យ និងពិគ្រោះពិភាក្សាលើរបាយការណ៍វឌ្ឍនភាពរយៈពេល៦ខែដើមឆ្នាំ២០១៨ និងទិសដៅបន្តរយៈពេល៦ខែចុងឆ្នាំ តាមរយៈការអនុម័តនូវសេចក្តីសម្រេចចិត្តរបស់ កិច្ចប្រជុំផងដែរ។

**៤. ពិធីអបអរសាទរសមិទ្ធផល២៥ឆ្នាំ នៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍**

អ.ជ.ប.ជ.អ បានរៀបចំពិធីអបអរសាទរសមិទ្ធផល២៥ឆ្នាំនៃការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ជាលក្ខណៈពហុវិស័យ និងការប្តេជ្ញាចិត្តឆ្ពោះទៅបញ្ចប់ការរាលដាលមេរោគអេដស៍នៅឆ្នាំ២០២៥។

**៥. យុទ្ធសាស្ត្រជានានិរន្តភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍**

- អ.ជ.ប.ជ.អ បានសហការជាមួយអង្គការ UNAIDS រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនទីបង្ហាញផ្លូវក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រកបដោយចីរភាពនៅកម្ពុជា។
- ក្រុមការងារធានានិរន្តរភាពនៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍បានរៀបចំកិច្ចប្រជុំ២លើក ដោយសម្រេចបានឯកសារវាយតម្លៃពីការត្រៀមឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍ ដែលមានផែនទីចង្អុលផ្លូវ (Roadmap) បង្ហាញពីការប្រឈម(Identified Risk) ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ដំណាក់កាលអន្តរកាល។

៦. អ.ជ.ប.ជ.អ បានដឹកនាំសម្របសម្រួលកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលមូលនិធិសកល កម្ពុជា(CCC) ដើម្បីពិភាក្សា និងពិនិត្យទៅលើវឌ្ឍនភាព និងលក្ខខណ្ឌសម្រាប់ការចាប់ផ្តើមនៃការអនុវត្ត គម្រោងកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់សម្រាប់ឆ្នាំ២០១៨ ដល់ឆ្នាំ២០២០។

៧. តំណែងប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកលត្រូវបានផ្ទេរពី**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងប្រធានគណៈកម្មាធិការសម្របសម្រួលមូលនិធិសកល (CCC) ជូនដល់ ឯកឧត្តម ហែម វណ្ណឌី អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានអាណត្តិថ្មីរបស់ CCC នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៨. អ.ជ.ប.ជ.អ បានដឹកនាំកិច្ចប្រជុំលើកទី២នៃយន្តការសម្របសម្រួលមូលនិធិសកលសម្រាប់មណ្ឌលតំបន់អាស៊ីប៉ាស៊ីហ្វិកខាងលិចនៃក្រុមប្រឹក្សាភិបាលមូលនិធិសកលនាថ្ងៃទី២៥ ខែមេសា ឆ្នាំ ២០១៨ នៅខេត្តសៀមរាបក្នុងនោះ**ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ត្រូវបានជ្រើសតាំងជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិសកលសម្រាប់មណ្ឌលតំបន់អាស៊ីប៉ាស៊ីហ្វិក។

**៩. ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី បានដឹកនាំការប្រជុំមណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច៖**

- ការធ្វើបច្ចុប្បន្នភាពអំពីកិច្ចប្រជុំគណៈកម្មាធិការបច្ចេកទេស ។
- ការពិនិត្យមើលលើរបៀបវារៈនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៤០។
- សេចក្តីប្រកាសរបស់មណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ។
- ការត្រៀមលក្ខណៈសម្រាប់ប្រតិភូមណ្ឌលតំណាងតំបន់ សមាសភាព តួនាទី និងការទទួលខុសត្រូវ។
- មតិលើគោលការណ៍ណែនាំប្រតិបត្តិការនៃមណ្ឌលតំណាងតំបន់ប៉ាស៊ីហ្វិកខាងលិច ។

**១០. កិច្ចប្រជុំគណៈកម្មាធិការយុទ្ធសាស្ត្រក្រុមប្រឹក្សាភិបាលមូលនិធិសកលនៅប្រទេសស្វីស**

ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៨ **ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងជាសមាជិកក្រុមប្រឹក្សាភិបាលមូលនិធិសកល បានដឹកនាំគណៈប្រតិភូទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការយុទ្ធសាស្ត្រនៃក្រុមប្រឹក្សាភិបាលមូលនិធិសកលនៅប្រទេសស្វីស។

**១១. ប្រជុំក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ**

អគ្គលេខាធិការដ្ឋានបានដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ ចំនួន១០លើក។

- ផ្សព្វផ្សាយសេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គ អ.ជ.ប.ជ.អ លើកទី២ ឆ្នាំ២០១៧ និងលើកទី១ ឆ្នាំ២០១៨។
- តាមដាន និងរៀបចំរបាយការណ៍វឌ្ឍនភាពស្តីពី ការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។
- ចែករំលែកចំណេះដឹង ជំនាញ និងបទពិសោធន៍ ថ្មីៗ ស្តីពីការឆ្លើយតបចំពោះមេរោគអេដស៍ និងជំងឺអេដស៍ ពីក្រសួងស្ថាប័ន និងអង្គការជាដៃគូ។

- ពិភាក្សាស្វែងរកដំណោះស្រាយការងារបច្ចេកទេស ជូនសមាជិកអ.ជ.ប.ជ.អ។
- អ.ជ.ប.ជ.អ បានទទួលអំណោយអាហារបំប៉នសុខភាពខេមប្រូប៊ីយូទិក(KEM Probiotic) ពីមូលនិធិគីណាល់ តំណាងដោយលោកឱសថបណ្ឌិត ហៃ លីអ៊ាង ប្រធានមូលនិធិ និងជាប្រធានសហគ្រាសផលិតឱសថប៉េប៉េអឹម និងក្រុមហ៊ុនខនហ្វីរលេ។

**១២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសម្របសម្រួលកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសថ្នាក់ជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្នុងចំណោម បុរសស្រលាញ់បុរស និងស្រីស្រស់ ដើម្បីតាមដានស្ថានភាពប្រឈម វឌ្ឍនភាពការងារ និងប្រសិទ្ធភាពនៃការអនុវត្តផែនការ។

**១៣.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ សហការជាមួយក្រសួងសាធារណការ និងដឹកជញ្ជូនបានរៀបចំគម្រោងការអនុវត្តកម្មវិធីយុទ្ធនាការ ផ្សព្វផ្សាយអប់រំ អំពីមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងសហគមន៍តាមបណ្តាយផ្លូវជាតិលេខ៣ (កំពត - វាលរេញ) និងផ្លូវជាតិលេខ៧ (ត្បូងឃ្មុំ-ក្រចេះ) ក្រោមគម្រោងគ្រប់គ្រងផ្លូវថ្នល់ទី២ (Road Asset Management Project-II: RAMP-II) ។

**១៤. វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តយុទ្ធសាស្រ្តចលនាប្រភពធនធាន**

- អ.ជ.ប.ជ.អ បន្តសហការជាមួយគណៈកម្មាធិការសម្របសម្រួលមូលនិធិសកល ក្នុងការបន្តស្វែងរកការគាំទ្រថវិកាជាបន្តទៀត នៅក្រោយឆ្នាំ២០១៩។
- អ.ជ.ប.ជ.អ បន្តសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបង្កើនថវិកាជាតិដើម្បីបំពេញនូវគម្លាតនៃការធ្លាក់ចុះនូវការគាំទ្រថវិកាអន្តរជាតិជាបន្តបន្ទាប់។
- អ.ជ.ប.ជ.អ បានបញ្ចប់នូវគម្រោងផែនការថវិកាជាតិឆ្នាំ២០១៩ ដើម្បីស្នើសុំការអនុម័តពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ៤.៥. យុទ្ធសាស្រ្តទី៥: បន្ត និងបង្កើតបរិស្ថានការគាំទ្រ តាមរយៈការយល់ដឹងនិងការអនុវត្តច្បាប់ និងគោលនយោបាយឱ្យកាន់តែប្រសើរឡើង

**១.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានសហការជាមួយសមាជិក និងដៃគូការងារបានរៀបចំបញ្ចប់សេចក្តីព្រាងគោលការណ៍ណែនាំជាតិស្តីពី " ការបង្ការការចម្លងមេរោគអេដស៍ជាសកលនៅតាមគ្រឹះស្ថានមិនមែនសុខាភិបាល " ។

**២.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.ជ.អ បានចុះផ្សព្វផ្សាយនូវនិយាមប្រតិបត្តិសម្រាប់បញ្ចូលកម្មវិធីអេដស៍ទៅក្នុងផែនការអភិវឌ្ឍ និងវិនិយោគឃុំ-សង្កាត់ នៅខេត្តឧត្តរមានជ័យ។

**៣. ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច**

- បានផ្សព្វផ្សាយច្បាប់អេដស៍ ចំនួន ៣លើក គឺនៅខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ខេត្តកំពត ដោយមានអ្នកចូលរួមសរុប ១០៨៨ នាក់/ស្រី ២៩៣ នាក់។

- បានបញ្ជ្រាបនូវការយល់ដឹងពាក់ព័ន្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ ពិសេសគោលការណ៍ ៣សូន្យ នៅគ្រប់វេទិកាផ្សព្វផ្សាយច្បាប់នានារបស់ក្រសួង បានចំនួន១៣លើក នៅ២០ ក្រុង-ស្រុក ក្នុង៩ខេត្ត មាន ខេត្តឧត្តរមានជ័យ កំពង់ស្ពឺ ព្រៃវែង បន្ទាយមានជ័យ បាត់ដំបង ខេត្តកំពត ខេត្តតាកែវ ខេត្តពោធិ៍សាត់ និងខេត្តប៉ៃលិន ដោយមានអ្នកចូលរួមសរុប ៧ ៦២៤ នាក់ / ស្រី ២៨៣៨ នាក់។

## ៤.៦. យុទ្ធសាស្ត្រទី៦: បង្កើនប្រព័ន្ធតាមដាន និងវាយតម្លៃការឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍តែមួយ (ជាយុទ្ធសាស្ត្រពាក់ព័ន្ធនឹងយុទ្ធសាស្ត្រ៥ទៀត)

### ៤.៦.១. ផែនការយុទ្ធសាស្ត្រជាតិ និងផែនការសកម្មភាព

- បានដឹកនាំក្រុមការងារថ្នាក់ជាតិធ្វើការពិនិត្យឡើងវិញ នូវផែនការយុទ្ធសាស្ត្រជាតិលើកទី៤ និងរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥(២០១៩-២០២៣)។
- បានចូលរួមផ្តល់ធាតុចូលស្តីពីការឆ្លើយតបទៅនឹងជំងឺអេដស៍សម្រាប់ធ្វើផែនការអភិវឌ្ឍជាតិរបស់រាជរដ្ឋាភិបាលឆ្នាំ២០១៩ ដល់ឆ្នាំ២០២៣ ដែលសម្របសម្រួលដោយក្រសួងផែនការ ។
- បានបញ្ចប់ផែនការប្រយុទ្ធនឹងជំងឺអេដស៍របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍សម្រាប់ឆ្នាំ២០១៩។
- បានបញ្ចប់ការរៀបចំផែនទីបង្ហាញផ្លូវថ្នាក់ជាតិ សម្រាប់ការលុបបំបាត់ការចម្លងមេរោគអេដស៍ និងស្វាយពីម្តាយទៅកូន រួមទាំង Poster និងឧបករណ៍តាមដានពាក់ព័ន្ធ ដោយការសហការរវាង NCHADS, NMCHC និង UNAIDS។

### ៤.៦.២. របាយការណ៍ជាតិ និងអន្តរជាតិ

- បានរៀបចំសេចក្តីព្រាងរបាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការឆ្លើយតបជាតិទូលំទូលាយ និងពហុវិស័យទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆ្នាំ២០១៨។
- បានបញ្ចប់សេចក្តីព្រាងរបាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍២០១៨ (GARPR 2018)ផ្ញើជូនទៅអង្គការសហប្រជាជាតិ។
- អ.ជ.ប.ជ.អ បានបញ្ចប់ការវិភាគទិន្នន័យ ស្តីពីការអង្កេតជាតិការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍លើកទី៦ ឆ្នាំ២០១៦ និង២០១៧ (NASA VI 2016-2017) និងរៀបចំសរសេររបាយការណ៍ ដោយការសហការ និងគាំទ្រពី UNAIDS, HP+។
- បានបញ្ចប់ការសិក្សាស្តីពី IBBS ធ្វើក្នុងចំណោមអ្នកប្រើប្រាស់ / អ្នកចាក់គ្រឿងញៀនដោយសម្របសម្រួលដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។

### ៤.៦.៣. ការផ្សព្វផ្សាយ និងការប្រើប្រាស់ព័ត៌មាន

#### ក. ការរៀបចំ និងផ្សព្វផ្សាយរបាយការណ៍

ជាលទ្ធផលសម្រាប់ឆ្នាំ២០១៨ នេះអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំជាបន្តបន្ទាប់នូវរបាយការណ៍វឌ្ឍនភាព និងសមិទ្ធិផលក្នុងទម្រង់ជាប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ២០១៨ របាយការណ៍វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍២០១៨ផ្ញើជូនទៅអង្គការសហប្រជាជាតិ(GARPR 2018) និងរបាយកាណ៍ស្តីពីការអង្កេតជាតិការចំណាយលើការប្រយុទ្ធនឹងជំងឺអេដស៍លើកទី៦ ឆ្នាំ២០១៦ និង២០១៧ (NASA VI 2016-2017) ជាភាសាខ្មែរ និងជាភាសាអង់គ្លេស ដើម្បីផ្ញើជូនទៅរាជរដ្ឋាភិបាល រដ្ឋសភាជាតិ ដៃគូអភិវឌ្ឍ និងធ្វើការផ្សព្វផ្សាយជាសាធារណៈ។

#### ខ. ការរៀបចំ និងផ្សព្វផ្សាយតាមគេហទំព័រ

អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបន្តគ្រប់គ្រង និងដាក់បញ្ចូលជាបន្តបន្ទាប់នូវឯកសារថ្មីៗ ទាំងអស់ដែលបានផលិតចេញដោយសមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ទាំងអស់។ នៅក្នុងឆ្នាំ២០១៨នេះ យើងមានឯកសារ និងព័ត៌មានថ្មីៗជាច្រើនដែលបានដាក់បញ្ចូលក្នុងគេហទំព័រជារួមបានចំនួន ១១៩ច្បាប់ មានអ្នកចូលអានសរុប ១៥៤៤៦៣នាក់ គិតត្រឹមថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ ដែលឯកសារទាំងនោះមាន វគ្គបណ្តុះបណ្តាល សិក្ខាសាលា កិច្ចប្រជុំថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ព្រមទាំងរបាយការណ៍ផ្សេងៗជាច្រើន ។

## ៥. សេចក្តីសន្និដ្ឋាន

១. យុទ្ធសាស្ត្រដឹកនាំ គ្រប់គ្រង និងសម្របសម្រួលការឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិបានប្រព្រឹត្តទៅតាមផែនការគ្រាន់តែចំនួនដង នៃកិច្ចប្រជុំមិនបានសម្រេចទៅតាមគោលដៅដែលបានកំណត់ទុកនោះទេ ដោយសារតែបញ្ហាគាំទ្រថវិកា។

២. យុទ្ធសាស្ត្របង្ការបានប្រព្រឹត្តទៅតាមផែនការជាពិសេសនៅក្នុងចំណោមក្រុមប្រឈមខ្ពស់ តែប្រឈមនឹងបញ្ហាគ្របដណ្តប់ទៅលើភូមិសាស្ត្រ និងក្រុមគោលដៅមិនបានគ្រប់ជ្រុងជ្រោយ ដោយសារតែមានអង្គការមួយចំនួនបានបញ្ចប់គម្រោងជាស្ថាពរ និងមិនទាន់មានអង្គការផ្សេងទៅជំនួសបានទាន់ពេលនៅឡើយ។

៣. ចំពោះព័ត៌មានស្តីពីវត្តមានស្រោមអនាម័យ គឺទទួលបានតែពីអង្គការមិនមែនរដ្ឋាភិបាល តែនៅកង្វះព័ត៌មានពីស្ថាប័នសាធារណៈ និងពីស្ថាប័នឯកជន(ក្រសួងសុខាភិបាល)។

៤. យុទ្ធសាស្ត្រថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ដោយឱសថប្រឆាំងនឹងមេរោគអេដស៍បានប្រព្រឹត្តទៅដោយរលូន និងប្រកបដោយប្រសិទ្ធភាព (៨៦% ៩៨% ៨០%) ប្រកបដោយក្តីសង្ឃឹមខ្ពស់ក្នុងការឈានទៅសម្រេចបាននូវគោលដៅ ៩០-៩០-៩០ ទាំងស្រុងនៅឆ្នាំ២០២០ ខាងមុខនេះ។

៥. យុទ្ធសាស្ត្រផ្តល់សេវាគាំទ្រសង្គមទៅដល់អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ និងជនរងគ្រោះដោយសារផលប៉ះពាល់នៃជំងឺអេដស៍គឺបានប្រព្រឹត្តទៅជាប្រចាំ តែនៅមានការលំបាក ក្នុងការញែកព័ត៌មានឲ្យដាច់ពីគ្នាជាមួយជនរងគ្រោះដែលគ្មានផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍។

៦. យុទ្ធសាស្ត្រកាត់បន្ថយការរើសអើងទៅលើអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍នៅកម្ពុជានៅតែបង្ហាញនូវសញ្ញាវិជ្ជមានក្នុងការឈានទៅបញ្ចប់ការរើសអើងទាំងស្រុង ព្រោះគ្មានរបាយការណ៍ពីករណីណាមួយ ស្តីពីការរើសអើងទៅលើអ្នកផ្ទុក មេរោគអេដស៍ និងជំងឺអេដស៍ទេ។

## ៦. ដែនកំណត់

នៅឆ្នាំ២០១៨នេះ ជាការកត់សំគាល់ឃើញថា ការផ្តល់របាយការណ៍មិនទាន់ពេលវេលា ឬមិនបានផ្ញើមក អ.ជ.ប.ជ.អ គឺបានប៉ះពាល់ដល់ការរៀបចំនូវរបាយការណ៍វឌ្ឍនភាពជាតិក្នុងការឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ ព្រោះថាវាជាការបាត់បង់នូវព័ត៌មានដែលតំណាងឱ្យការឆ្លើយតបជាតិទាំងមូល។ ទោះជាយ៉ាងណាក៏ដោយ ក៏ការផ្ញើទិន្នន័យមកកាន់ អ.ជ.ប.ជ.អ មានលក្ខណៈល្អប្រសើរជាងឆ្នាំមុនៗ ទាំងបរិមាណ និងគុណភាព។

ចំពោះសមាជិក អ.ជ.ប.ជ.អ ដែលបានផ្ញើទិន្នន័យ ឬរបាយការណ៍មក អ.ជ.ប.ជ.អ គឺនៅមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយគឺនៅមានគម្លាត និងខ្វះសុក្រិតភាពនៃទិន្នន័យ ឬព័ត៌មានឧទាហរណ៍ គម្លាតចំនួនក្រុមគោលដៅ គម្លាតចំនួនសេវា។ល។

ភាពយឺតយ៉ាវនៃការទទួលបាននូវថវិកាជំនួយសម្រាប់ការចំណាយ នាំឱ្យប៉ះពាល់យ៉ាងខ្លាំងទៅដល់ការ ពន្យាពេលក្នុងការអនុវត្តសកម្មភាពគន្លឹះមួយចំនួនដូចជាកិច្ចប្រជុំដឹកនាំ គ្រប់គ្រង និងសម្របសម្រួលរបស់គណៈកម្មាធិការ និងលេខាធិការដ្ឋានប្រយុទ្ធនឹងជំងឺអេដស៍ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៧. អនុសាសន៍

១. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងដៃគូអភិវឌ្ឍរៀបចំបញ្ចប់ និងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣ និងយុទ្ធសាស្ត្រជាតិជានាថីរភាព សម្រាប់ឆ្លើយតបការងារប្រយុទ្ធនឹងជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បញ្ចូលសកម្មភាពដែលបានលើកឡើង នៅក្នុងផែនទីចង្អុលផ្លូវ នៃការឆ្លើយតបដោយចីរភាពទៅក្នុងផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ ឆ្នាំ២០១៩-២០២៣។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវសហការជាមួយក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីផ្តល់ថវិកាអនុវត្តការបញ្ជ្រាបការងារប្រយុទ្ធនឹងមេរោគអេដស៍ ជំងឺអេដស៍ទៅក្នុងផែនការអភិវឌ្ឍរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ ឃុំ សង្កាត់។

៤. ក្រសួងសុខាភិបាល និងក្រសួងផែនការត្រូវកំណត់ថាអ្នកផ្ទុកមេរោគអេដស៍ជាក្រុមប្រជាជនងាយរងគ្រោះដែលត្រូវទទួលបានអត្តសញ្ញាណគ្រួសារក្រីក្រ និងមូលនិធិសមធម៌ដែលធានាដល់ការទទួលបានសេវាថែទាំសុខភាព និងការគាំពារសង្គម។

៥. ក្រសួងសុខាភិបាល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវកែសម្រួលនិងរៀបចំវិធាន និងនីតិវិធីក្នុងការផ្តល់ថវិកាដើម្បីឱ្យស្រុកប្រតិបត្តិ មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាពមានថវិកាផ្ទាល់សម្រាប់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

៦. ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសុខាភិបាល និងអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវទទួលស្គាល់តួនាទីសំខាន់របស់អង្គការសង្គមស៊ីវិលក្នុងការឆ្លើយតបនឹងមេរោគអេដស៍ ជំងឺអេដស៍ និងបន្តគាំទ្រឱ្យមានការចូលរួមបន្តទៀតតាមរយៈការផ្តល់មូលនិធិពីរាជរដ្ឋាភិបាល តាមលទ្ធភាពថវិកាជាតិ។

៧. ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិត្រូវសិក្សាលំហថវិកា ដើម្បីធានាការអនុវត្តការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបញ្ចប់បញ្ហាអេដស៍នៅក្នុងឆ្នាំ២០២៥។

៨. ក្រសួងសុខាភិបាលត្រូវបន្តពង្រឹងធនធានមនុស្ស ការធ្វើលទ្ធកម្ម ការផ្គត់ផ្គង់ឱសថបរិក្ខារ និងប្រព័ន្ធព័ត៌មាន ដើម្បីបញ្ជ្រាបការឆ្លើយតបការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ឱ្យកាន់តែមានប្រសិទ្ធភាព និងធានាចីរភាព។

## ឯកសារយោង

១. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលនៃការអនុវត្តគម្រោងផែនការសកម្មភាពឆ្លើយតបទូលំទូលាយ និងពហុវិស័យទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ប្រចាំឆមាសទី២ ឆ្នាំ២០១៨។

២. កំណត់ហេតុកិច្ចប្រជុំពេញអង្គសមាជិកអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ និងលើកទី២ ឆ្នាំ២០១៨។

៣. របាយការណ៍វឌ្ឍនភាព និងសមិទ្ធផលរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង រាជធានី ខេត្ត។

៤. របាយការណ៍សកម្មភាព និងសមិទ្ធផលការងារប្រយុទ្ធនឹងជំងឺអេដស៍ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិលផ្ញើមកអគ្គលេខាធិការ អ.ជ.ប.ជ.អ ។

៥. សេចក្តីសម្រេចចិត្តកិច្ចប្រជុំពេញអង្គអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី២ ឆ្នាំ២០១៨។